អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens



**24th December 2019**

# STATEMENT BY THE INTERNATIONAL CO-PROSECUTOR ON CASE 004/2

In accordance with Internal Rule 54 of the ECCC, Brenda J. Hollis issues this public statement setting forth her position regarding the effect of the Pre-Trial Chamber's recent disposition of appeals in case 004/2.

On 19 December 2019, the Pre-Trial Chamber of the Extraordinary Chambers in the Courts of Cambodia ("ECCC") delivered its *Considerations on Appeal Against Closing Orders* in the case against AO An, Case 004/2, ("Considerations").

Contrary to some media reports, the Pre-Trial Chamber's Considerations do *not* acquit AO An or conclude the case.

These Considerations dispose of the appeals against the differing legal conclusions reached by the two Co-Investigating Judges in 2018 upon the completion of their investigation into crimes alleged against AO An. One Investigating Judge indicted AO An for international crimes and violations of the Cambodian Criminal Code and sent him to trial. The other Investigating Judge dismissed the case against him because he did not consider that AO An falls within the ECCC's personal jurisdiction.

The Pre-Trial Chamber uses the term "Considerations" rather than "Decision" because under the ECCC's governing law a "decision" requires agreement of at least four of the five judges of the Pre-Trial Chamber, known as a "supermajority", and this supermajority was not reached. Instead, the judges were split: three judges upheld the Dismissal Order and annulled the Indictment, whereas the other two judges annulled the Dismissal Order and upheld the Indictment, with some amendments.

The Internal Rules of the ECCC set out what happens when, like here, the Pre-Trial Chamber cannot reach the required supermajority on an appeal of an indictment. The Internal Rules of the ECCC consolidate Cambodian procedure and the laws which created the ECCC and provide direction for the ECCC judges and parties in carrying out the Court's mandate. Rule 77(13)(b) provides that in this case the default decision of the Pre-Trial Chamber is that the Trial Chamber must be "seised" of the indictment of the Co-Investigating Judges. Rule 1(2) defines Co-Investigating Judges to mean both of them acting jointly *and* each of them acting individually. Consequently, when read together, these Rules provide that where, as here, an indictment issued by one Co-Investigating Judge is not overturned by four of the five judges of the Pre-Trial Chamber, the case is sent to trial.

Following these Internal Rules, the two judges who upheld the Indictment (as amended) against AO An approved that he be sent to trial and ordered that the Trial Chamber be "seised" of the amended Indictment. To implement this ruling, they instructed that the amended Indictment, the Pre-Trial Chamber's "Considerations" document, and the Case

004/2 case file be forwarded to the Trial Chamber so that a trial against AO An can commence.

The International Co-Prosecutor will therefore act in accordance with the ECCC's Internal Rules and prepare for trial.



ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ ២០១៩

# សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីសំណុំរឿង ០០៤/២

អនុលោមតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក លោកស្រី Brenda J. Hollis ចេញសេចក្តីប្រកាសព័ត៌មានជាសាធារណៈអំពីគោលជំហររបស់ខ្លួន អំពីអានុភាពនៃផ្នែកសម្រេចសេចក្តីថ្មីៗនេះរបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/២។

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“អ.វ.ត.ក”) បានចេញ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* របស់ខ្លួនក្នុងរឿងក្តីប្រឆាំងនឹង អោ អាន ក្នុងសំណុំរឿង ០០៤/២ (“សេចក្តីពិចារណា”)។

ផ្ទុយទៅនឹងសេចក្តីរាយការណ៍សារព័ត៌មានមួយចំនួន សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ *មិនឲ្យ* អោ អាន រួចខ្លួន ឬបិទបញ្ចប់រឿងក្តីនេះទេ។

សេចក្តីពិចារណាទាំងនេះ សម្រេចបញ្ចប់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសន្និដ្ឋានផ្នែកច្បាប់ខុសគ្នាដែលបានសម្រេចដោយសហចៅក្រមស៊ើបអង្កេតពីររូបក្នុងឆ្នាំ ២០១៨ នៅពេលបញ្ចប់កិច្ចស៊ើបសួររបស់ពួកគេលើឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់ប្រឆាំងនឹង អោ អាន។ សហចៅក្រមស៊ើបអង្កេតម្នាក់បានចោទប្រកាន់ អោ អាន ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងការរំលោភលើក្រមព្រហ្មទណ្ឌប្រទេសកម្ពុជា និងបានបញ្ជូនគាត់ទៅជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតម្នាក់ទៀត បានលើកលែងការចោទប្រកាន់ប្រឆាំងនឹងគាត់ ដោយសារតែគាត់មិនចាត់ទុកថា អោ អាន ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

អង្គបុរេជំនុំជម្រះប្រើពាក្យ "សេចក្តីពិចារណា" មិនមែន "សេចក្តីសម្រេច" ទេ ដោយហេតុថា តាមច្បាប់គ្រប់គ្រង អ.វ.ត.ក "សេចក្តីសម្រេច" តម្រូវឲ្យមានការឯកភាពគ្នាយ៉ាងហោចណាស់ចៅក្រមបួនរូបក្នុងចំណោមចៅក្រមទាំងប្រាំរូបនៃអង្គបុរេជំនុំជម្រះ ដែលហៅថា "សំឡេងភាគច្រើនលើសលុប" ហើយសំឡេងភាគច្រើនលើសលុបនេះមិនទទួលបានទេ។ ផ្ទុយទៅវិញ ចៅក្រមត្រូវបានបំបែក៖ មានចៅក្រមបីរូបបានតម្កល់ដីកាសម្រេចលើកលែងចោទប្រកាន់ និងបានមោឃៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចំណែកឯចៅក្រមពីររូបទៀតបានមោឃៈដីកាសម្រេចលើកលែងចោទប្រកាន់ និងបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមានការកែប្រែមួយចំនួន។

វិធានទាំងនេះកំណត់អំពីអ្វីដែលកើតឡើង ដូចក្នុងករណីនេះ នៅពេលដែលអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនលើសលុបដែលតម្រូវបាន នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ វិធានផ្ទៃក្នុងនៃ អ.វ.ត.ក រួមបញ្ចូលនូវនីតិវិធីរបស់ប្រទេសកម្ពុជា និងច្បាប់ដែលបានបង្កើត អ.វ.ត.ក និងផ្តល់ទិសដៅសម្រាប់ចៅក្រម អ.វ.ត.ក និងភាគីនានាក្នុងការអនុវត្តអាណត្តិរបស់តុលាការនេះ។ វិធាន ៧៧(១៣)(ខ) ចែងថា ក្នុងករណីបែបនេះ សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គបុរេជំនុំជម្រះ គឺថាអង្គជំនុំជម្រះសាលាដំបូងត្រូវបាន "ប្តឹងឲ្យទទួលយក" ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត។ វិធាន ១(២) នៃវិធានផ្ទៃក្នុង កំណត់និយមន័យអំពីសហចៅក្រមស៊ើបអង្កេត ដែលមានន័យថា ពួកគាត់ទាំងពីរបំពេញកិច្ចរួមគ្នា *និង* ចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ។ ជាលទ្ធផល នៅពេលអានរួមគ្នា វិធានទាំងនេះចែងថា ក្នុងករណី ដូចនៅពេលនេះ ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតម្នាក់ មិនត្រូវបានបដិសេធដោយចៅក្រមបួនរូបក្នុងចំណោមចៅក្រមទាំងប្រាំរូបនៅអង្គបុរេជំនុំជម្រះទេនោះ រឿងក្តីត្រូវបញ្ជូនទៅជំនុំជម្រះ។

តាមរយៈវិធានផ្ទៃក្នុងទាំងនេះ ចៅក្រមទាំងពីររូបដែលបានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ដូចដែលបានកែប្រែ) ប្រឆាំងនឹង អោ អាន បានអនុម័តិថា អង្គជំនុំជម្រះសាលាដំបូងត្រូវបាន "ប្តឹងឲ្យទទួលយក" ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែនេះ។ ដើម្បីអនុវត្តសេចក្តីសម្រេចនេះ ពួកគាត់បានណែនាំថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានកែប្រែ ឯកសារនៃ "សេចក្តីពិចារណា" របស់អង្គបុរេជំនុំជម្រះ និងសំណុំរឿងនៃរឿងក្តី ០០៤/២ ត្រូវបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យការជំនុំជម្រះក្តីប្រឆាំងនឹង អោ អាន អាចចាប់ផ្តើមបាន។

អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិនឹងបំពេញកិច្ចស្របតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក និង ត្រៀមរៀបចំសម្រាប់ការជំនុំជម្រះ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីប្រកាសព័ត៌មានរបស់សហព្រះរាជអាជ្ញាជាតិ ទាក់ទងនឹងជនត្រូវចោទ អោ អាន ក្នុងសំណុំរឿងលេខ០០៤/២

យោងតាមវិធាន ៥៤ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញាជាតិ លោកស្រី **ជា លាង** សូមធ្វើសេចក្តីប្រកាសជាសាធារណៈ ទាក់ទងទៅនឹងជនត្រូវចោទ **អោ អាន** ក្នុងសំណុំរឿងលេខ០០៤/២ ដូចខាងក្រោម៖

កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ដែលសហព្រះរាជអាជ្ញាជាតិប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចំណែកឯ សហព្រះរាជអាជ្ញាអន្តរជាតិប្តឹងឧទ្ធរណ៍នឹងដីកាដំណោះស្រាយ (ដីកាសម្រេចលើកលែងចោទប្រកាន់)។

ក្នុងសេចក្តីសម្រេចនេះ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទ៖ (ដកស្រង់ផ្នែកពាក់ព័ន្ធ)

> **ប្រកាស ថាការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក។**

អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវតវ៉ា។

អនុលោមតាមវិធាន ៧៧ (១៤) នៃវិធានផ្ទៃក្នុង ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ត្រូវជូនដំណឹងទៅដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងភាគីនានា អំពីសាលដីកានេះ។

ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ដែលមានសម្លេង៣/៥ សម្រេចតម្កល់ដីកាដំណោះស្រាយលើកលែងចោទប្រកាន់ **អោ អាន** ទុកជាបានការ ហើយសម្រេចទុកជាមោឃៈដីកាដំណោះស្រាយចោទប្រកាន់ **អោ អាន** ជូនទៅជំនុំជម្រះ ដោយយល់ឃើញថា ការដែលសហចៅក្រមស៊ើបអង្កេតទាំងពីរ ចេញដីកាដំណោះស្រាយពីរ មានខ្លឹមសារផ្ទុយគ្នា ជាការរំលោភទាំងស្រុងទៅលើក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក និងការដែលសហចៅក្រមស៊ើបអង្កេតទាំងពីរ បានគេចចេញពីការខ្វែងយោបល់គ្នា ដែលត្រូវបានដោះស្រាយតាមវិធាន ៧២ នៃវិធានផ្ទៃក្នុង បង្កើតបានជាឧបសគ្គដ៏ស្រួចស្រាវមួយ ពុំមានលទ្ធភាពដោះស្រាយសមស្របតាមគតិច្បាប់ឡើយ ព្រមទាំងវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង ពុំបានគ្រោងទុក ឬក៏ពុំអាចលើកជាវិធានការសម្រាប់ដោះស្រាយការជាប់គាំង ដោយសារមូលហេតុមានដីកាដំណោះស្រាយពីរមានខ្លឹមសារផ្ទុយគ្នា ដូចករណី សំណុំរឿង០០៤/២ នេះឡើយ។

ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ ដែលមានសម្លេង២/៥ សម្រេចបញ្ជូន **អោ អាន** ទៅជំនុំជម្រះ តាមវិធាន ៧៧ (១៣) (ខ) នៃវិធានផ្ទៃក្នុង ដោយយល់ឃើញថា ដោយសារតែមិនមានសម្លេងភាគច្រើនលើសលប់ របស់អង្គបុរេជំនុំជម្រះ និងដោយសារតែស្ថានភាពពិសេសនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដែលផ្ទុយគ្នា។

សហព្រះរាជអាជ្ញាជាតិសង្កេតឃើញថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺខុសច្បាប់ ស្របតាមអំណាចសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលបាន**ប្រកាស**ថា "**ការចេញដីកាដំណោះស្រាយពីរ ដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តរបស់ អ.វ.ត.ក**"។

សហព្រះរាជអាជ្ញាជាតិ កត់សម្គាល់ឃើញថា នៅក្នុងសេចក្តីសម្រេចដោយសម្លេងឯកច្ឆ័ន្ទខាងលើរបស់ខ្លួនពាក់ព័ន្ធនឹងជនត្រូវចោទ **អោ អាន** អង្គបុរេជំនុំជម្រះមិនបានសម្រេចឱ្យក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបញ្ជូនសេចក្តីសម្រេច ឬសំណុំរឿងនេះឡើយ ចំណែកឯក្នុងសេចក្តីសម្រេចកន្លងមកពីមុនៗ របស់អង្គបុរេជំនុំជម្រះ បង្គាប់ឱ្យក្រឡាបញ្ជីរបស់ខ្លួនបញ្ជូនសេចក្តីសម្រេច ឬសំណុំរឿង។


ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោក **នេត្រ ភក្ត្រា**
ប្រធានផ្នែកកិច្ចការសាធារណៈនិងជាអ្នកនាំពាក្យ
ទូរស័ព្ទចល័ត+៨៥៥)០)១២ ៤៨៨ ១៥៦
អ៊ីមែល៖ neth.phektra@eccc.gov.kh

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**December 24, 2019**

# PRESS STATEMENT

**National Co-Prosecutor's Press Statement on the Charged Person AO An of Case 004/2**

Pursuant to Rule 54 of the Internal Rule of the ECCC, **Mrs. CHEA Leang** hereby issues a public statement regarding the Charged Person **AO An** of Case 004/2, as the following:

On 19 December 2019, the Pre-Trial Chamber issued its decision on Appeals of which the National Co-Prosecutor appealed against the Closing Order (Indictment) whereas the International Co-Prosecutor appealed against the Closing Order (Dimissal).

In this Decision, the Pre-Trial Chamber unanimously: (cited relevant parts)

> **Declares** that **the Co-Investigating Judges' issuance of the Two Conflicting Closing Orders was illegal, violating the legal framework of the ECCC.**

In accordance with Rule 77(13) of the Internal Rules, the present Decision is not subject to appeal.

In accordance with Internal Rule 77(14), this Decision shall be notified to the Co-Investigating Judges, the Co-Prosecutors and the parties by the Greffier of the Pre-Trial Chamber.

The National Judges of the Pre-Trial Chamber, with 3/5 votes, decided to uphold the Closing Order (Dismissal) dismissing the case against **AO An** as valid. They held to annul the Closing Order (Indictment) to send **AO An** for trial since they are of the views that the two Co-Investigating Judges who issued two conflicting Closing Orders are in the violations of the ECCC's legal frameworks in its entirety and that the two Co-Investigating Judges have departed from settling their disagreements in conformity with Rule 72 of the Internal Rules, which created a solid obstacle beyond the capacity to be solved in accordance with the laws; whereas the Rule 77(13) of the Internal Rules do not anticipate or unable to bring up any measure for settlement of this deadlock due to the two Closing Orders had two different substances as for the Case 004/2.

The International Judges of the Pre-Trial Chamber, with 2/5 votes, held that **AO An** is indicted and committed to trial in accordance with Rule 77(13)(b) and that because of the Pre-Trial Chamber's failure in attaining the required supermajority and the exceptional circumstance of the Appeals against the conflicting Closing Orders.

The National Co-Prosecutor is of the view that the International Co-Investigating Judges' Closing Order (Indictment) is illegal based on the effect of the Pre-Trial Chamber's decision, **declaring** that "**the Co-Investigating Judges' issuance of the Two Conflicting Closing Orders was illegal, violating the legal framework of the ECCC**".

In the above Pre-Trial Chamber's decision which is unanimusly declared on the Charged Person **AO An**, the National Co-Prosecutor noted that the Pre-Trial Chamber did not order that the Greffier of the PTC forwards the decision or this casefile, whereas in the previous PTC's decisions it ordered that the decision or the casefile be forwared by the Greffier.

***For further information, please contact:***

Mr. NETH Pheaktra
Chief of Public Affairs Office, Press Officer
Mobile: +855 (0) 12 488 156
Email: neth.phektra@eccc.gov.kh